# ការិយាល័យមេធាវីសិទ្ធិស័ក្តិ
## បច្ចុប្បន្នភាពគតិយុត្តប្រចាំខែ

កក្កដា ឆ្នាំ ២០១៧

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ពន្ធអាករ**

### ប្រកាសលេខ ៥៥៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ

ប្រកាសនេះមានគោលបំណងណែនាំអនុវត្ត**អាករលើតម្លៃបន្ថែម**ចំពោះការផ្គត់ផ្គង់មិនជាប់អាករ ស្របតាម**មាត្រា ៥៧** នៃ**ច្បាប់ស្តីពីសារពើពន្ធ** ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

គោលដៅរបស់ប្រកាសនេះគឺដើម្បីកំណត់ឱ្យច្បាស់លាស់នូវទំនិញ ឬសេវាមួយចំនួនដែលជាកម្មវត្ថុនៃការផ្គត់ផ្គង់មិនជាប់អាករ ដើម្បីជានាបាននូវសង្គតិភាពក្នុងការអនុវត្តអាករលើតម្លៃបន្ថែម ជម្រុញសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើការប្រើប្រាស់ទំនិញ ឬសេវាចាំបាច់មួយចំនួនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ការផ្គត់ផ្គង់ទំនិញ ឬសេវាដែលមិនជាប់អាករលើតម្លៃបន្ថែមរួមមាន៖

១. សេវាប្រៃសណីយ៍សាធារណៈ
២. សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ ដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ
៣. សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
៤. សេវាធានារ៉ាប់រង
៥. សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ
៦. ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ដែលរួចពន្ធគយស្របតាមបទប្បញ្ញត្តិស្តីពីគយ។

“**សិទ្ធិស័ក្តិ**” សំដៅដល់អំណាចនៃការសម្រេចឧត្តមប្រយោជន៍នៃយុត្តិធម៌ តាមរយៈអត្ថន័យ “**ទេវរាជ**” ជាស្តេចនៃទេវតាទ្រង់យាងព្រះរាជដំណើរដោយគង់ប្រថាប់លើព្រះទីនាំង “**នាគរាជ**” ដែលតំណាងឲ្យអធិតេយ្យដែនដីខ្មែរតាំងពីបុរាណកាលតរៀងមក ដើម្បីប្រទាន “ទេវាយុត្តិធម៌” ដល់មនុស្សជាតិដោយអនុភាពនៃទេវឬទ្ធិដែលតំណាងដោយ “**ព្រះខ័ន**”។

**សិទ្ធិស័ក្តិ មានបទពិសោធន៍ជំនាញ ជាអាទិ៍÷**

- ច្បាប់ក្រុមហ៊ុន និងច្បាប់ពាណិជ្ជកម្ម ច្បាប់ធានារ៉ាប់រង ច្បាប់កិច្ចសន្យា ច្បាប់វិនិយោគ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ការងារ
- វិស័យធនាគារ និងហិរញ្ញវត្ថុ វិស័យសារពើពន្ធ វិស័យថាមពល រ៉ែនិងហេដ្ឋារចនាសម្ព័ន្ធ វិស័យអចលនទ្រព្យ និងសំណង់ វិស័យមូលបត្រ
- វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការងារ
- កិច្ចការកំណែទម្រង់ច្បាប់ និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- សេវាបកប្រែ និងបញ្ជាក់លិខិតស្នាម

www.sithisaklawoffice.com
023 63 73 168
contact@sithisak-lawoffice.com
Sithisak law office
Sithisak law office



ផ្ទះលេខ ១៣A ផ្លូវ៣៣៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
N° 13A, St 334 Sangkat Boeung Keng Kang I, Khan Chamkamorn, Phnom Penh, Kingdom of Cambodia.
Tel: (855) 23 6373 168 Email: contact@sithisak-lawoffice.com www.sithisak-lawoffice.com

៧. សកម្មភាពមិនស្វែងរកប្រាក់ចំណេញដើម្បីបម្រើផលប្រយោជន៍សាធារណៈ

៨. សេវាសិក្សាអប់រំ

៩. ថាមពលអគ្គិសនី និងទឹកស្អាត

១០. ផលិតផលកសិកម្មមិនទាន់កែច្នៃ

១១. សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ។

**ប្រកាសលេខ ៥១៨ សហវ.ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ**

ប្រកាសនេះមានគោលបំណងណែនាំអនុវត្តពន្ធកាត់ទុក លើការបែងចែកភាគលាភ ដូចមានចែងក្នុងមាត្រា ២៦ ថ្មី (មួយ) និងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។ ប្រកាសនេះ បានដាក់ចេញនូវវិធានសម្រាប់កំណត់អំពីការអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភដែលអ្នកជាប់ពន្ធនិវាសនជនទូទាត់ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជនដែលត្រូវអនុវត្ត ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ។

ភាគលាភសំដៅដល់ចំណែកជាសាច់ប្រាក់ ឬទ្រព្យដែលនីតិបុគ្គលបានបែងចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែការបែងចែកមូលធន ឬដើមទុនក្នុងពេលជម្រះបញ្ជីរំលាយក្រុមហ៊ុន។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភ ឬមិនមែនភាគលាភ ត្រូវផ្អែកតាមលក្ខខណ្ឌខាងលើនេះដោយពុំគិតថានីតិបុគ្គលមាន ឬគ្មានប្រាក់ចំណូលសុទ្ធក្នុងឆ្នាំចរន្ត ឬពីឆ្នាំមុនៗឡើយ។

**កិច្ចដែលជាប់ពន្ធកាត់ទុក និងមិនជាប់ពន្ធកាត់ទុក៖**

-ភាគលាភដែលបានបែងចែកដោយអ្នកជាប់ពន្ធនិវាសនជន ទៅឱ្យអ្នកជាប់ពន្ធអនិវាសនជន ត្រូវជាប់ពន្ធកាត់ទុកតាមអត្រា ១៤% នៃទឹកប្រាក់ត្រូវបើក។

"**សិទ្ធិស័ក្តិ**" សំដៅដល់អំណាចនៃការសម្រេចឧត្តមប្រយោជន៍នៃយុត្តិធម៌ តាមរយៈអត្ថន័យ "**ទេវរាជ**" ជាស្តេចនៃទេវតាទ្រង់យាងព្រះរាជដំណើរដោយគង់ប្រថាប់លើព្រះទីនាំង "**នាគរាជ**" ដែលតំណាងឲ្យអធិតេយ្យដែនដីខ្មែរតាំងពីបុរាណកាលតរៀងមក ដើម្បីប្រទាន "ទេវាយុត្តិធម៌" ដល់មនុស្សជាតិដោយអនុភាពនៃទេវឫទ្ធិដែលតំណាងដោយ "**ព្រះខ័ន**"។

**សិទ្ធិស័ក្តិ មានបទពិសោធន៍ជំនាញ ជាអាទិ៍÷**

- ច្បាប់ក្រុមហ៊ុន និងច្បាប់ពាណិជ្ជកម្ម ច្បាប់ធានារ៉ាប់រង ច្បាប់កិច្ចសន្យា ច្បាប់វិនិយោគ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ការងារ
- វិស័យធនាគារ និងហិរញ្ញវត្ថុ វិស័យសារពើពន្ធ វិស័យថាមពល រ៉ែនិងហេដ្ឋារចនាសម្ព័ន្ធ វិស័យអចលនទ្រព្យ និងសំណង់ វិស័យមូលបត្រ
- វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការងារ
- កិច្ចការកំណែទម្រង់ច្បាប់ និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- សេវាបកប្រែ និងបញ្ជាក់លិខិតស្នាម


www.sithisaklawoffice.com

023 63 73 168

contact@sithisak-lawoffice.com

Sithisak law office

Sithisak law office





ផ្ទះលេខ ១៣A ផ្លូវ៣៣៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Nº 13A, St 334 Sangkat Boeung Keng Kang I, Khan Chamkamorn, Phnom Penh, Kingdom of Cambodia.

Tel: (855) 23 6373 168 Email: contact@sithisak-lawoffice.com www.sithisak-lawoffice.com

ការទូទាត់ភាគលាភឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់។

- ការលក់ភាគហ៊ុន ឬបែងចែកមូលធន ឬដើមទុន ទោះក្នុងពេលប្រកបអាជីវកម្ម ឬពេលជម្រះបញ្ជីរំលាយក្រុមហ៊ុនក្តី ចំណែកភាគហ៊ុន ឬមូលធន ឬដើមទុន ដែលបានមកពីការបង្វែរចេញពីប្រាក់ចំណូលរក្សាទុក <u>ត្រូវជាប់ពន្ធកាត់ទុក</u>។

- ការបង្វែរចំណែកណាមួយ ឬទាំងស្រុងនៃប្រាក់ចំណូលរក្សាទុកទៅក្នុងមូលធន ឬដើមទុនរបស់សហគ្រាស <u>មិនត្រូវបានចាត់ទុកជាការបែងចែកភាគលាភ</u> និង <u>មិនជាប់ពន្ធកាត់ទុក</u>ទេ តែចាំបាច់ត្រូវមានការសម្រេចពីក្រុមប្រឹក្សាភិបាល និងមានភស្តុតាងច្បាស់លាស់អំពីការកែប្រែមូលធនដោយមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច។

***ចំណាំ៖ សម្រាប់គោលដៅនៃពន្ធកាត់ទុក ទឹកប្រាក់ភាគលាភដែលបានកត់ត្រាបែងចែកក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់។**

**ប្រកាសលេខ ៥៥៧ សហវ.ប្រក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៧**

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៧ ត្រូវប្រមូលចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៧ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារ កាណាឌីយ៉ា ក.អ ឬនៅធនាគារ អេស៊ីលីដាភីអិលស៊ី ឬនៅធនាគារ កម្ពុជាសាធារណៈភីអិលស៊ី ឬនៅធនាគារ វឌ្ឍនៈ ឬនៅធនាគារ អេ អិន ហ្សេត រ៉ូយ៉ាល់។

“**សិទ្ធិស័ក្តិ**” សំដៅដល់អំណាចនៃការសម្រេចឧត្តមប្រយោជន៍នៃយុត្តិធម៌ តាមរយៈអត្ថន័យ “**ទេវរាជ**” ជាស្តេចនៃទេវតាទ្រង់យាងព្រះរាជដំណើរដោយគង់ប្រថាប់លើព្រះទីនាំង “**នាគរាជ**” ដែលតំណាងឲ្យអធិតេយ្យដែនដីខ្មែរតាំងពីបុរាណកាលតរៀងមក ដើម្បីប្រទាន “ទេវាយុត្តិធម៌” ដល់មនុស្សជាតិដោយអនុភាពនៃទេវឫទ្ធិដែលតំណាងដោយ “**ព្រះខ័ន**”។

**សិទ្ធិស័ក្តិ មានបទពិសោធន៍ជំនាញ ជាអាទិ៍÷**

- ច្បាប់ក្រុមហ៊ុន និងច្បាប់ពាណិជ្ជកម្ម ច្បាប់ធានារ៉ាប់រង ច្បាប់កិច្ចសន្យា ច្បាប់វិនិយោគ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ការងារ
- វិស័យធនាគារ និងហិរញ្ញវត្ថុ វិស័យសារពើពន្ធ វិស័យថាមពល រ៉ែនិងហេដ្ឋារចនាសម្ព័ន្ធ វិស័យអចលនទ្រព្យ និងសំណង់ វិស័យមូលបត្រ
- វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការងារ
- កិច្ចការកំណែទម្រង់ច្បាប់ និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- សេវាបកប្រែ និងបញ្ជាក់លិខិតស្នាម

www.sithisaklawoffice.com
023 63 73 168
contact@sithisak-lawoffice.com
Sithisak law office
Sithisak law office



ផ្ទះលេខ ១៣A ផ្លូវ៣៣៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Nº 13A, St 334 Sangkat Boeung Keng Kang I, Khan Chamkamorn, Phnom Penh, Kingdom of Cambodia.
Tel: (855) 23 6373 168 Email: contact@sithisak-lawoffice.com www.sithisak-lawoffice.com

**ដើម្បីបង់ពន្ធ ម្ចាស់យានយន្តត្រូវភ្ជាប់មកជាមួយនូវ៖**

**ក. ចំពោះម្ចាស់យានយន្តដែលមានប័ណ្ណសម្គាល់ការបង់ពន្ធប្រភេទនេះ៖**

+ ប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយមិនចាំបាច់ដាក់លិខិតប្រកាសបង់ពន្ធ
+ ករណីបាត់ប័ណ្ណនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំបោះពុម្ពប័ណ្ណបង់ពន្ធសារជាថ្មីនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅសាខាណាមួយនៃធនាគារទាំងប្រាំខាងលើដោយត្រូវបង់កម្រៃសេវាក្នុងការធ្វើប័ណ្ណនេះចំនួន ៥០០០ រៀល។

**ខ. ចំពោះម្ចាស់យានយន្តដែលមិនមានប័ណ្ណសម្គាល់ការបង់ពន្ធប្រភេទនេះ៖**

+ ត្រូវបំពេញ និងដាក់លិខិតប្រកាសបង់ពន្ធចំនួន ២ សន្លឹក ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារបង់ពន្ធឆ្នាំ២០១៦
+ ករណីបាត់ឯកសារបង់ពន្ធនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធសម្រាប់ឆ្នាំ២០១៦ នៅសាខាន្ធដារខេត្ត-ខណ្ឌ ដើម្បីប្រើប្រាស់ក្នុងការបង់ពន្ធសម្រាប់ឆ្នាំ២០១៧។

**គ. ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទដែលទើបមកប្រកាសបង់ពន្ធលើកដំបូង៖**

+ ត្រូវបំពេញ និងដាក់លិខិតប្រកាសបង់ពន្ធចំនួន ២ សន្លឹកដោយត្រូវភ្ជាប់មកជាមួយនូវ៖
  - ប័ណ្ណសម្គាល់យានយន្ត ឬ
  - វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ចេញដោយក្រសួង សាធារណការនិងដឹកជញ្ជូន ឬ
  - បង្កាន់ដៃបង់ពន្ធនាំចូល

“**សិទ្ធិស័ក្តិ**” សំដៅដល់អំណាចនៃការសម្រេចឧត្តមប្រយោជន៍នៃយុត្តិធម៌ តាមរយៈអត្ថន័យ “**ទេវរាជ**” ជាស្តេចនៃទេវតាទ្រង់យាងព្រះរាជដំណើរដោយគង់ប្រថាប់លើព្រះទីនាំង “**នាគរាជ**” ដែលតំណាងឱ្យអធិតេយ្យដែនដីខ្មែរតាំងពីបុរាណកាលតរៀងមក ដើម្បីប្រទាន “ទេវាយុត្តិធម៌” ដល់មនុស្សជាតិដោយអនុភាពនៃទេវឫទ្ធិដែលតំណាងដោយ “**ព្រះខ័ន**”។

**សិទ្ធិស័ក្តិ មានបទពិសោធន៍ជំនាញ ជាអាទិ៍÷**

- ច្បាប់ក្រុមហ៊ុន និងច្បាប់ពាណិជ្ជកម្ម ច្បាប់ធានារ៉ាប់រង ច្បាប់កិច្ចសន្យា ច្បាប់វិនិយោគ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ការងារ
- វិស័យធនាគារ និងហិរញ្ញវត្ថុ វិស័យសារពើពន្ធ វិស័យថាមពល រ៉ែនិងហេដ្ឋារចនាសម្ព័ន្ធ វិស័យអចលនទ្រព្យ និងសំណង់ វិស័យមូលបត្រ
- វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការងារ
- កិច្ចការកំណែទម្រង់ច្បាប់ និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- សេវាបកប្រែ និងបញ្ជាក់លិខិតស្នាម


www.sithisaklawoffice.com
023 63 73 168
contact@sithisak-lawoffice.com
Sithisak law office
Sithisak law office





ផ្ទះលេខ ១៣A ផ្លូវ៣៣៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
N° 13A, St 334 Sangkat Boeung Keng Kang I, Khan Chamkamorn, Phnom Penh, Kingdom of Cambodia.
Tel: (855) 23 6373 168 Email: contact@sithisak-lawoffice.com www.sithisak-lawoffice.com

- លិខិតបញ្ជាក់ការប្រើប្រាស់យានយន្តចេញដោយឃុំ-សង្កាត់ ចំពោះយានយន្តកែ ច្នៃក្នុងស្រុក និង
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតបញ្ជាក់សំបុត្រកំណើតចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឬលិខិតឆ្លងដែនរបស់ម្ចាស់យានយន្ត។

**ឃ. ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដែលបានបង់ពន្ធឆ្នាំកន្លងមក ហើយត្រូវបានប្តូរប័ណ្ណសម្គាល់យានយន្តថ្មី៖**

+ ម្ចាស់យានយន្តត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្តដើម្បីប្រកាសបង់ពន្ធបន្ត និង
+ ប្តូរប័ណ្ណសម្គាល់ការបង់ពន្ធ ក្នុងករណីរថយន្តនោះត្រូវបានប្តូរស្លាកលេខ។

**ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបានលើកលែងចំពោះ៖**

+ រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យជាកម្មសិទ្ធិរបស់រដ្ឋ
+ យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រាជរដ្ឋាភិបាលនានា
+ យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់កិច្ចការពារជាតិ ជាមធ្យោបាយប្រើប្រាស់ដឹកជញ្ជូនសម្ភារទ័ព ឬដឹកជញ្ជូនកងទ័ព ក៏ដូចជាសម្រាប់កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដូចមានចែងក្នុងមាត្រា ១១ និងមាត្រា ១២ នៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ និងយានយន្តដែលពាក់ស្លាកលេខ ខ.ម ឬ ន.ប ជាផ្លូវការ ដែលមានការទទួលស្គាល់ និងបញ្ជាក់ពីក្រសួងការពារជាតិ ឬក្រសួងមហាផ្ទៃ។


"**សិទ្ធិស័ក្តិ**" សំដៅដល់អំណាចនៃការសម្រេចឧត្តមប្រយោជន៍នៃយុត្តិធម៌ តាមរយៈអត្ថន័យ "**ទេវរាជ**" ជាស្តេចនៃទេវតាទ្រង់យាងព្រះរាជដំណើរដោយគង់ប្រថាប់លើព្រះទីនាំង "**នាគរាជ**" ដែលតំណាងឲ្យអធិតេយ្យដែនដីខ្មែរតាំងពីបុរាណកាលតរៀងមកដើម្បីប្រទាន "ទេវាយុត្តិធម៌" ដល់មនុស្សជាតិដោយអនុភាពនៃទេវឫទ្ធិដែលតំណាងដោយ "**ព្រះខ័ន**"។

**សិទ្ធិស័ក្តិ មានបទពិសោធន៍ជំនាញ ជាអាទិ៍÷**

- ច្បាប់ក្រុមហ៊ុន និងច្បាប់ពាណិជ្ជកម្ម ច្បាប់ធានារ៉ាប់រង ច្បាប់កិច្ចសន្យា ច្បាប់វិនិយោគ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ការងារ
- វិស័យធនាគារ និងហិរញ្ញវត្ថុ វិស័យសារពើពន្ធ វិស័យថាមពល រ៉ែនិងហេដ្ឋារចនាសម្ព័ន្ធ វិស័យអចលនទ្រព្យ និងសំណង់ វិស័យមូលបត្រ
- វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការងារ
- កិច្ចការកំណែទម្រង់ច្បាប់ និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- សេវាបកប្រែ និងបញ្ជាក់លិខិតស្នាម

www.sithisaklawoffice.com
023 63 73 168
contact@sithisak-lawoffice.com
Sithisak law office
Sithisak law office

ក្រសួង-ស្ថាប័ន ឬអង្គភាពដែលជាអាណាព្យាបាល ឬជាម្ចាស់កម្មសិទ្ធិនៃយានយន្តដូចបានកំណត់នេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធ (ពន្ធជាបន្ទុករបស់រដ្ឋ) ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌយានយន្តរបស់ក្រសួង-ស្ថាប័ន ឬអង្គភាពដែលបានស្នើសុំនោះ។

**ទណ្ឌកម្ម៖**

យានយន្តគ្រប់ប្រភេទដែលខកខាន ឬមិនបានបង់ពន្ធសម្រាប់បណ្តាឆ្នាំកន្លងមក ត្រូវបង់ពន្ធ និងប្រាក់ពិន័យឱ្យបានរួចរាល់ជាមុនសិន ទើបអនុញ្ញាតឱ្យប្រកាសបង់ពន្ធសម្រាប់ឆ្នាំ២០១៧។ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨តទៅ យានយន្តទាំងឡាយណាដែលមិនបានប្រកាសបង់ពន្ធតាមការកំណត់នឹងត្រូវទទួលការផាកពិន័យ។

"**សិទ្ធិស័ក្តិ**" សំដៅដល់អំណាចនៃការសម្រេចឧត្តមប្រយោជន៍នៃយុត្តិធមិ តាមរយៈអត្ថន័យ "**ទេវរាជ**" ជាស្តេចនៃទេវតាទ្រង់យាងព្រះរាជដំណើរដោយគង់ប្រថាប់លើព្រះទីនាំង "**នាគរាជ**" ដែលតំណាងឲ្យអធិតេយ្យដែនដីខ្មែរតាំងពីបុរាណកាលតរៀងមក ដើម្បីប្រទាន "ទេវាយុត្តិធមិ" ដល់មនុស្សជាតិដោយអនុភាពនៃទេវឫទ្ធិដែលតំណាងដោយ "**ព្រះខ័ន**"។

**សិទ្ធិស័ក្តិ មានបទពិសោធន៍ជំនាញ ជាអាទិ៍÷**

- ច្បាប់ក្រុមហ៊ុន និងច្បាប់ពាណិជ្ជកម្ម ច្បាប់ធានារ៉ាប់រង ច្បាប់កិច្ចសន្យា ច្បាប់វិនិយោគ ច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ការងារ
- វិស័យធនាគារ និងហិរញ្ញវត្ថុ វិស័យសារពើពន្ធ វិស័យថាមពល រ៉ែនិងហេដ្ឋារចនាសម្ព័ន្ធ វិស័យអចលនទ្រព្យ និងសំណង់ វិស័យមូលបត្រ
- វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម និងការងារ
- កិច្ចការកំណែទម្រង់ច្បាប់ និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត
- សេវាបកប្រែ និងបញ្ជាក់លិខិតស្នាម


www.sithisaklawoffice.com
023 63 73 168
contact@sithisak-lawoffice.com
Sithisak law office
Sithisak law office





ផ្ទះលេខ ១៣A ផ្លូវ៣៣៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Nº 13A, St 334 Sangkat Boeung Keng Kang I, Khan Chamkamorn, Phnom Penh, Kingdom of Cambodia.
Tel: (855) 23 6373 168 Email: contact@sithisak-lawoffice.com www.sithisak-lawoffice.com